មជ្ឈមណ្ឌលឯកសារកម្ពុជា

# ការធ្វើបទបង្ហាញ និងបញ្ចាំងភាពយន្តឯកសារ នៅសកលវិទ្យាល័យភ្នំពេញអន្តរជាតិ

## ក្រុមសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម និងគេហទំព័រឃ្លាំមើលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

*ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១*

នៅព្រឹកថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ ក្រុមការងារគម្រោងគេហទំព័រឃ្លាំមើលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ហៅកាត់ថា ស៊ី ធី អឹម (CTM) និងក្រុមសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមបានធ្វើបទបង្ហាញមួយនៅសកលវិទ្យាល័យភ្នំពេញអន្តរជាតិ ព្រមទាំងចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ សៀវភៅប្រល័យពូជសាសន៍ សៀវភៅសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមលេខទី៣ និងឯកសារណែនាំអំពីគេហទំព័រឃ្លាំមើលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដល់និស្សិតចំនួន៨០នាក់ ។

### ១) ការធ្វើបទបង្ហាញអំពីគេហទំព័រឃ្លាំមើលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

ជាការចាប់ផ្តើមនៅក្នុងការធ្វើបទបង្ហាញនេះ សា ហ្វាទីលី បានចាក់បញ្ចាំងខ្សែភាពយន្តឯកសារមួយដែលរៀបរាប់ពីប្រទេសកម្ពុជាមុនរបបខ្មែរក្រហម ក្នុងរបបខ្មែរក្រហម និងក្រោយរបបខ្មែរក្រហមបានដួលរលំ ។ ក្រោយពីការបញ្ចាំងខ្សែភាពយន្តបានបញ្ចប់ គឹម សុវណ្ណដានី ជំនួយការប្រធានក្រុមគេហទំព័រឃ្លាំមើលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ក៏បានសួរសំណួរទាក់ទងនឹងចំណាប់អារម្មណ៍របស់និស្សិតដែលចូលរួមថា «តើប្អូនៗទាំងអស់គ្នាបានយល់ដឹងអ្វីខ្លះពីរបបខ្មែរក្រហម ឬរបបកម្ពុជាប្រជាធិបតេយ្យនេះ?» ។

បន្ទាប់មក ដានី បានលើកទឹកចិត្តឲ្យសិស្ស-និស្សិតងាកមកចាប់អារម្មណ៍ពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ និងធ្វើការស្រាវជ្រាវតាមដានពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលកំពុងដំណើរការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឬហៅថា តុលាការខ្មែរក្រហម ។ ក្រោយមកទៀត ដានី បានបង្ហាញពីរបៀបប្រើប្រាស់គេហទំព័រឃ្លាំមើលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះ របៀបចូលទៅកាន់គេហទំព័រស្វែងរកព័ត៌មានអំពីប្រវត្តិសាស្ត្រកម្ពុជា និងការស្វែងរកព័ត៌មានពាក់ព័ន្ធនឹងតុលាការខ្មែរក្រហម ដូចជា វីដេអូស្តីពីដំណើរការសវនាការ ព័ត៌មានដែលប្រកាសចេញពីតុលាការ និងអត្ថបទដែលសរសេរពាក់ព័ន្ធនឹងដំណើរការប្រព្រឹត្តទៅរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាដើម ។ មុននឹងបញ្ចប់ការធ្វើបទបង្ហាញនេះ ដានី បានលើកទឹកចិត្តដល់និស្សិតខ្មែរទាំងអស់ឲ្យប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណែត ដើម្បីជាប្រយោជន៍កសាងចំណេះដឹងដល់ខ្លួន មិនត្រូវឲ្យអ៊ិនធឺណែតទាញយកប្រយោជន៍ ឬធ្វើឲ្យអ្នកប្រើប្រាស់ខាតបង់ប្រយោជន៍ឡើយ ។

## ២) ការធ្វើបទបង្ហាញពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម

### គម្រោងសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម និងសារសំខាន់នៃការស្វែងយល់ពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម

ក្រោយពី ដានី រៀបរាប់រួច គីម ម៉ារីយ៉ាន ជាសមាជិកម្នាក់ក្នុងចំណោមសមាជិកទាំងបួននាក់ (គីម ម៉ារីយ៉ាន, ចាន ប្រាថ្នា, ឌី សុជាតា និង លីម ជ័យទត្ត) នៃក្រុមសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមក៏បានធ្វើការណែនាំស្តីអំពីគោលបំណងនៃគម្រោង ។ ម៉ារីយ៉ាន បានបង្ហាញអំពីគោលដៅចម្បងៗរបស់គម្រោងសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមថា គម្រោងនេះមានគោលដៅផ្សព្វផ្សាយពីដំណើរវិវត្តន៍របស់តុលាការ និងពន្យល់ពីនីតិវិធីនៅក្នុងដំណើរការកាត់ទោសលើសំណុំរឿង០០២ដល់ប្រជាជនកម្ពុជាទាំងអស់ឲ្យបានយល់ដឹងកាន់តែទូលំទូលាយ ។ ការផ្សព្វផ្សាយនេះធ្វើឡើងតាមរយៈការចែកជូនសៀវភៅដែលរៀបរាប់អំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយចេញផ្សាយជារៀងរាល់ខែដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ម៉ារីយ៉ាន ក៏បានលើកឡើងនូវគោលដៅសំខាន់មួយទៀតគឺការបង្កើតឲ្យមានការប្រកួតប្រជែងសរសេរជាអត្ថបទដែលមានលក្ខណៈជាអត្ថបទស្រាវជ្រាវ និងវិភាគផ្នែកច្បាប់សម្រាប់និស្សិតកម្ពុជា ។ បន្ទាប់ពីការណែនាំខ្លួន ក៏ដូចជាការណែនាំគម្រោងសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមរួចមក ម៉ារីយ៉ាន បានបន្ថែមថា ការស្វែងយល់ពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ពិតជាមានសារសំខាន់ណាស់សម្រាប់ប្រជាជនកម្ពុជា និងសិស្សានុសិស្ស ជាពិសេស និស្សិតដែលសិក្សាផ្នែកច្បាប់ ។ គោលដៅសំខាន់នៅក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺដើម្បីផ្តល់យុត្តិធម៌ដល់ប្រជាជនកម្ពុជាដែលបានទទួលរងគ្រោះដោយសាររបបខ្មែរក្រហមនិងដើម្បីទប់ស្កាត់កុំឲ្យអំពើប្រល័យពូជសាសន៍ និងអំពើអមនុស្សធម៌កើតមានសាជាថ្មីនៅក្នុងសង្គមជាតិកម្ពុជាទៅថ្ងៃអនាគត ។

### បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងសំណុំរឿង០០១

ប្រាថ្នា បានលើកឡើងថា នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសផ្តន្ទាទោសជនជាប់ចោទឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ពីបទប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល៣៥ឆ្នាំ ។ ប្រាថ្នា បានបន្តថា ការផ្តន្ទាទោសនេះត្រូវបានបន្ថយមកនៅត្រឹមរយៈពេល១៩ឆ្នាំ ដោយសារតែ ឌុច ធ្លាប់ត្រូវបានឃុំខ្លួនដោយខុសនីតិវិធីច្បាប់នៅក្នុងតុលាការយោធា និងទូទាត់ចំពោះរយៈពេលដែល ឌុច ត្រូវបានឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំងចាប់តាំងពីពេលចាប់ខ្លួននៅឆ្នាំ១៩៩៩ រហូតចេញសាលក្រម ។

ប្រាថ្នា បានបញ្ជាក់ថា សហព្រះរាជអាជ្ញាបានផ្តោតទៅលើមូលដ្ឋានពីរសំខាន់ក្នុងការប្តឹងឧទ្ធរណ៍ គឺ ការកំណត់បទល្មើស និងការកំណត់ទោសលើជនជាប់ចោទ ។ ចំពោះមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍របស់

សហមេធាវីការពារក្តីឲ្យ ឌុច គឺថា ឌុច មិនស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ និងថា ការផ្តន្ទាទោស ឌុច ត្រូវតែផ្អែកទៅលើក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ។ រីឯបណ្តឹងឧទ្ធរណ៍របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺពាក់ព័ន្ធនឹងការច្រានចោលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅពេលប្រកាសសាលក្រម និងការផ្តល់សំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី ។

## សវនាការបឋមលើសម្បទាជនជាប់ចោទនៅក្នុងសំណុំរឿង០០២និងស្ថានភាពសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ

ឌី សុជាតា បានពន្យល់ពីដំណើរការសវនាការនៅថ្ងៃទី ២៩-៣១ ខែសីហា ឆ្នាំ២០១១ ស្តីពីសម្បទាលើសុខភាពផ្លូវកាយ និងបញ្ហាស្មារតីរបស់ជនជាប់ចោទនៅក្នុងសំណុំរឿង០០២ ក្នុងការធ្វើការចូលរួមសវនាការ ដែលសមត្ថភាពក្នុងការចូលរួមសវនាការប្រកបដោយប្រសិទ្ធភាពនេះ រួមមានសមត្ថភាពក្នុងការទំនាក់ទំនងផ្តល់ព័ត៌មានជាមួយមេធាវីរបស់ខ្លួន សមត្ថភាពក្នុងការយល់ដឹងពីបទចោទ សមត្ថភាពយល់ដឹងពីលទ្ធផលនៃនីតិវិធី សមត្ថភាពក្នុងការធ្វើសក្ខីកម្ម ។ សុជាតា បានបន្ថែមថា សមត្ថភាពទាំងនេះជាមធ្យោបាយធានានូវគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ និងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ និងយុត្តិធម៌ ។ សុជាតា បានបន្តថា សវនាការបឋមធ្វើឡើងដោយសារតែជនជាប់ចោទនៅក្នុងសំណុំរឿង០០២មានវ័យចំណាស់ ហើយអ្នកខ្លះមានជំងឺថែមទៀត ។ នៅក្នុងសវនាការបឋមលើសម្បទារបស់ជនជាប់ចោទក្នុងសំណុំរឿង០០២ លោកសាស្ត្រាចារ្យ ចន ខាំប៊ែល បានស្នើសុំឲ្យមានការវិនិច្ឆ័យពីអ្នកជំនាញបន្ថែមទៀតលើបញ្ហាសុខភាព បញ្ញា ស្មារតី របស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ ហេតុដូច្នេះហើយទើបនៅថ្ងៃទី១៩-២០ ខែកញ្ញា ឆ្នាំ២០១១ មានសវនាការបឋមមួយទៀតដែលធ្វើឡើងដើម្បីធ្វើការដេញដោលលើរបាយការណ៍របស់អ្នកជំនាញពីររូបទៀត ដើម្បីបញ្ជាក់ពីស្ថានភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។

## ការបំបែកសំណុំរឿង០០២ និងតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងរឿងព្រហ្មទណ្ឌនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

លីម ជ័យទត្ត បានធ្វើបទបង្ហាញពីការបំបែកសំណុំរឿងនៅក្នុងករណី០០២ និងតួនាទីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីក្នុងសវនាការ ។ ជ័យទត្ត បានលើកឡើងថា ការបំបែកសំណុំរឿងធ្វើឡើង គឺដើម្បីជួយពន្លឿនដល់ដំណើរការនីតិវិធីក្នុងការកាត់សេចក្តីនៅក្នុងសំណុំរឿង០០២ ឲ្យកាន់តែឆាប់រហ័ស ដោយសារតែជនជាប់ចោទទាំងបួនរូបសុទ្ធតែមានវ័យចំណាស់ និងមានបញ្ហាសុខភាពថែមទៀត ។ ហេតុនេះការចេញសេចក្តីសម្រេចបំបែកសំណុំរឿងនៅក្នុងករណី០០២ អាចនឹងធានាដល់ការផ្តល់យុត្តិធម៌ជូនទាំងជនរងគ្រោះ និងជនជាប់ចោទ ថែមទាំងធានានូវគោលការណ៍ស្មើភាពគ្នា ចំពោះមុខច្បាប់ និងសិទ្ធិក្នុងការទទួលបានការកាត់សេចក្តីដោយឆាប់រហ័ស ។ ជ័យទត្ត បានពន្យល់បន្ថែមពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាថា ដើមបណ្តឹង

រដ្ឋប្បវេណីនៅក្នុងបរិបទសាលាក្ដីកាត់ទោសមេដឹកនាំខ្មែរក្រហម គឺសំដៅលើជនរងគ្រោះ ដែលទទួលរងព្យសនកម្ម(ការខូចខាត) កើតចេញពីអំពើឧក្រិដ្ឋដែលបានប្រព្រឹត្តនៅរវាងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ ជ័យទត្ត បានបន្តថា ជនរងគ្រោះមានពីរប្រភេទ គឺជនរងគ្រោះដែលទទួលរងព្យសនកម្មដោយផ្ទាល់ពីឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងរបបខ្មែរក្រហម និងជនរងគ្រោះដែលទទួលរងព្យសនកម្មដោយប្រយោលរួមមាន សាច់ញាតិ ក្រុមគ្រួសាររបស់ជនរងគ្រោះ ដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ ជ័យទត្ត បានពន្យល់អំពីការទទួលបានសំណងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាថា សំណងដែលដើមបណ្ដឹងរដ្ឋប្បវេណីអាចទទួលបានមានពីរប្រភេទគឺ សំណងជាសមូហភាព និងសំណងផ្លូវចិត្ត ។

## ៣) ការឆ្លើយសំណួរ

បន្ទាប់ពីការទស្សនាខ្សែភាពយន្តខ្លី និងការធ្វើបទបង្ហាញរួចមក គឺមានការសួរសំណួរខ្លះៗទាក់ទងនឹងដំណើរការនៃការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ សំណួរដំបូងទាក់ទងនឹងគោលបំណងនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សុជាតា បានឆ្លើយតបថា គឺដើម្បីស្វែងរកយុត្តិធម៌ និងការផ្សះផ្សាជូនដល់ប្រជាជនកម្ពុជា និងឲ្យតុលាការនេះក្លាយជាគំរូដល់តុលាការក្នុងស្រុក ។ រីឯ សំណួរទីពីរថាតើនរណាខ្លះជាជនរងគ្រោះ? ជ័យទត្ត បានឆ្លើយតបថា នៅក្នុងបរិបទនៃសាលាក្ដីខ្មែរក្រហម ជនរងគ្រោះ គឺជាជនទាំងឡាយណាដែលទទួលរងព្យសនកម្មដោយផ្ទាល់ ឬដោយប្រយោលពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងសម័យខ្មែរក្រហម ។ ចំណែកសំណួរមួយទៀតបានសួរថា ហេតុអ្វីបានជាតុលាការនាំខ្លួន ឌុច មកកាត់ទោស បើ ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់? ប្រាថ្នា បានឆ្លើយតប ដោយពន្យល់អំពីសិទ្ធិអំណាចដែលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមានដើម្បីកាត់ទោសទៅលើបុគ្គលពីរប្រភេទ គឺមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ហើយ ឌុច ត្រូវបានតុលាការចាត់ចូលទៅក្នុងក្រុមបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុតនេះ ។ ចំពោះសំណួរបន្ទាប់ដែលសួរពីមូលហេតុនាំឲ្យកាត់ទោស កាំង ហ្កេកអ៊ាវ ហៅ ឌុច មុនជនជាប់ចោទដ៏ទៃទៀត ម៉ារីយ៉ាន បានឆ្លើយអំពីការទទួលបានភស្តុតាង សាក្សី និងការស៊ើបអង្កេតដែលមានលក្ខណៈគ្រប់គ្រាន់នៅក្នុងសំណុំរឿង០០១ ជាងសំណុំរឿង ០០២ ។ ម៉ារីយ៉ាន បានបន្តទៀតថា ដោយសារតែសំណុំរឿង០០២ មានដើមបណ្ដឹងរដ្ឋប្បវេណីច្រើននាក់ និងត្រូវការពេលវេលាដើម្បីស៊ើបអង្កេតបន្ថែម ។ដូច្នេះសំណុំរឿង០០២ ត្រូវជម្រះនៅពេលក្រោយ ។ ចំពោះសំណួរបន្ទាប់ គឺបានសួរដោយលោកសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ដែលលោកមានចម្ងល់អំពីច្បាប់ណាខ្លះដែលត្រូវអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ប្រាថ្នា បានឆ្លើយតបថា តុលាការនេះមានច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងវិធានផ្ទៃក្នុងដែលបានចែងអំពីការអនុវត្តនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញមួយនេះ ហើយក្នុងករណីដែលមានការខ្វះចន្លោះ គឺត្រូវអនុវត្តតាមបទដ្ឋានអន្តរជាតិ ។ បន្ទាប់ពីសំណួរខាងលើ គឺនៅមានសំណួរមួយចំនួនទៀតដែលបានសួរមកកាន់ក្រុមអ្នកសង្កេតការណ៍ដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

### ៤) មតិរបស់សិស្ស

បន្ទាប់ពីសំណួរ និងចម្លើយបានបញ្ចប់ ដើម្បីចង់ដឹងអំពីមតិរបស់និស្សិតទាំងអស់នៅក្នុងសិក្ខាសាលានេះ ដានី បានបំផុសសំណួរដល់ក្រុមនិស្សិតអំពីចំណាប់អារម្មណ៍របស់ខ្លួននៅក្នុងការចូលរួមស្តាប់ការធ្វើបទបង្ហាញរបស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ បន្ទាប់មក និស្សិតច្បាប់ឆ្នាំទី២នៅសាកលវិទ្យាល័យភ្នំពេញអន្តរជាតិបានបញ្ចេញពីទស្សនៈរបស់ខ្លួនថា ការចូលរួមនៅក្នុងថ្ងៃនេះ គឺជាចំណេះដឹងមួយយ៉ាងទូលំទូលាយបំផុតសម្រាប់និស្សិត និងប្រជាជនខ្មែរទាំងមូលដែលធ្លាប់ឆ្លងកាត់ក្នុងរបបខ្មែរក្រហមក្នុងការយល់ដឹងអំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ និស្សិតរូបនេះ បានបន្តទៀតថា ចំពោះការផ្សព្វផ្សាយតាមគេហទំព័រអំពីតុលាការនេះ គឺជាការបង្ហាញឲ្យពិភពលោក បានដឹងថា ប្រជាជនខ្មែរបានទទួលរងបទល្មើសប្រល័យពូជសាសន៍ដ៏សាហាវឃោរឃៅ ហើយយើងមិនគួរឲ្យមានអំពើបែបនេះកើតឡើងតទៅទៀតនៅក្នុងប្រទេសណាមួយទេ ។ មាននិស្សិតនារីមួយរូបទៀត បានឡើងបញ្ចេញមតិរបស់ខ្លួនថា ការធ្វើបទបង្ហាញនេះមានអត្ថប្រយោជន៍ខ្លាំងណាស់សម្រាប់និស្សិតផ្នែកច្បាប់ព្រោះធ្វើឲ្យយើងមានភាពងាយស្រួលក្នុងការស្រាវជ្រាវឯកសារមួយចំនួនតាមរយៈគេហទំព័រនេះ ។ ចំណែកនិស្សិតធនាគារឆ្នាំទី២ក៏មានភាពក្លាហានឡើងផ្តល់នូវចំណាប់អារម្មណ៍របស់ខ្លួនថា ការធ្វើបទបង្ហាញនេះមានអត្ថប្រយោជន៍ជាខ្លាំងសម្រាប់និស្សិត មិនត្រឹមតែនិស្សិតផ្នែកច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែបានផ្តល់នូវចំណេះដឹងដល់និស្សិតដែលរៀនផ្នែកផ្សេងទៀតឲ្យបានយល់ដងដែរ ។ ជាពិសេសចំពោះរបបប្រល័យពូជសាសន៍នេះ គឺមិនមែនជួបប្រទះតែនៅក្នុងប្រទេសកម្ពុជាទេ សូម្បីប្រទេសផ្សេងក៏ជួបប្រទះបញ្ហាដូចគ្នានេះដែរ ។ ដូច្នេះការកាត់ក្តីនេះ គឺអាចផ្តល់ព័ត៌មានយ៉ាងទូលំទូលាយដល់ប្រជាជនមិនត្រឹមតែក្នុងស្រុកទេ ថែមទាំងនៅក្រៅស្រុកផងដែរឲ្យបានយល់ដឹងអំពីដំណើរការរបស់តុលាការខ្មែរក្រហម ។ ចុងក្រោយនិស្សិត និងព្រះសង្ឃមួយចំនួនទៀត បានឡើងផ្តល់មតិ និងថ្លែងអំណរគុណដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានធ្វើបទបង្ហាញនៅក្នុងថ្ងៃនេះ ព្រមទាំងបានបញ្ចេញពីទស្សនៈមួយចំនួនស្រដៀងគ្នានឹងមតិរបស់និស្សិតខាងលើផងដែរ ។ ការធ្វើបទបង្ហាញនេះបានបញ្ចប់នៅម៉ោងប្រមាណជិតម៉ោង ១២ថ្ងៃត្រង់ ។